ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ.......១៤២.......ស.ភ.រ

# សេចក្តីសម្រេច

## ស្តីពី

## បេក្ខជនដែលត្រូវបំពេញបន្ថែមសំណុំឯកសារដើម្បីទទួលបានសិទ្ធិចូលរួមប្រឡង ត្រួតពិនិត្យសមត្ថភាពចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យម នៅសាលាភូមិន្ទរដ្ឋបាល ឆ្នាំសិក្សា ២០១៦

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្របក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់សាលាភូមិន្ទរដ្ឋបាលលេខ ៥៥១ ស.ភ.រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២
- យោងលិខិតលេខ១៥១ មស.សករ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ស្តីពីសំណើចាត់តាំងមន្ត្រីរាជការស៊ីវិលចូលរួមប្រឡងជ្រើសរើសចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល
- យោងលិខិតរបស់ក្រសួងមុខងារសាធារណៈស្តីពីសំណើចាត់តាំងមន្ត្រីនគរបាលជាតិនៃក្រសួងមហាផ្ទៃចំនួន ២០ រូប ដើម្បីចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យមសម្រាប់ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល
- យោងលិខិតរបស់ក្រសួងមុខងារសាធារណៈស្តីពីសំណើចាត់តាំងយោធិនចំនួន២០រូប ដើម្បីចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យមសម្រាប់ ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល
- យោងសេចក្តីសម្រេចលេខ ៨៩០ មស. សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីលក្ខណៈវិនិច្ឆ័យជ្រើសរើសបេក្ខជនចូលរៀនវគ្គវិក្រឹត្យការ នៅសាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៦
- យោងសេចក្តីសម្រេច ១០៨ ស.ភ.រ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ស្តីពីការចាត់តាំងគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដើម្បីចូលរួមប្រឡងចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមធ្យម នៅសាលាភូមិន្ទរដ្ឋបាល



អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាឃ្លាំងមឿង (៤៦៦) ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

## សម្រេច

**ប្រការ១៖** បេក្ខជនទាំងពីរភេទដែលមានរាយនាមដូចខាងក្រោមត្រូវមកបំពេញបន្ថែមសំណុំឯកសារ ដើម្បីជាមូលដ្ឋានសម្រាប់គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដើម្បីចូលរួមប្រឡងចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមធ្យម នៅសាលាភូមិន្ទរដ្ឋបាល ធ្វើការវាយតម្លៃផ្តល់ឲ្យ ឬមិនផ្តល់ឲ្យសិទ្ធិប្រឡង៖

| ល.រ | គោត្តនាម នាម | | ភេទ | ថ្ងៃខែឆ្នាំកំណើត | ក្រសួង - ស្ថាប័ន |
|---|---|---|---|---|---|
| ១ | ប៉ុល | សារុណា | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ២ | នេត | បញ្ញា | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣ | ម៉ែន | ចរិយា | ស | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤ | ឆេង | វណ្ណារ៉ា | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥ | រិន | រ៉ាវុធ | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៦ | កែ | ឧត្តម | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៧ | ឃួន | លឹមឈាន់ | ប | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៨ | ឡាយ | សុភីរ៉េត | ប | | ក្រសួងសុខាភិបាល |
| ៩ | សេក | នារីរ័ត្ន | ស | | ក្រសួងសុខាភិបាល |
| ១០ | លាវ | ប៊ុណ្ណារិទ្ធ | ប | | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ១១ | គង់ | រាប | ប | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១២ | ផៃ | សុផល | ប | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៣ | ធុង | វ៉ៃ | ប | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៤ | ហុក | សុចិត្រា | ប | | ក្រសួងមហាផ្ទៃ |
| ១៥ | សេង | សុខកែប | ប | | ក្រសួងមហាផ្ទៃ |
| ១៦ | សុខ | ចំរើន | ប | | ក្រសួងមហាផ្ទៃ |
| ១៧ | កុយ | សុខគុន | ប | | ក្រសួងមហាផ្ទៃ |
| ១៨ | សរ | សុផល | ប | | ក្រសួងមហាផ្ទៃ |
| ១៩ | ម៉ើង | លីដា | ប | | ក្រសួងមហាផ្ទៃ |
| ២០ | ខៀវ | ភារិទ្ធ | ប | | ក្រសួងមហាផ្ទៃ |
| ២១ | ញាណ | ចន្ទាវ៉ា | ប | | ក្រសួងមហាផ្ទៃ |
| ២២ | វ៉ាន់ | ណារី | ប | | ក្រសួងមហាផ្ទៃ |
| ២៣ | យេល | សុខជា | ស | | ក្រសួងមហាផ្ទៃ |
| ២៤ | ខេង | ម៉េងឈុន | ប | | ក្រសួងមហាផ្ទៃ |
| ២៥ | សោម | ផល្លា | ប | | ក្រសួងមហាផ្ទៃ |

| ល.រ | គោត្តនាម នាម | | ភេទ | ថ្ងៃខែឆ្នាំកំណើត | ក្រសួង - ស្ថាប័ន |
|---|---|---|---|---|---|
| ២៦ | ធាង | តុលា | ប | | រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល |
| ២៧ | ព្រាប | កុយវឌ្ឍនះ | ប | | រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល |
| ២៨ | ជាលី | ឫទ្ធី | ប | | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ២៩ | ជា | មុនធី | ស | | អគ្គលេខាធិការដ្ឋាន និងខុទ្ទកាល័យ រដ្ឋសភា |
| ៣០ | ជា | គីមវ៉ាន្នី | ប | | អាជ្ញាធរសវនកម្មជាតិ |
| ៣១ | ហេង | ម៉ារ៉ា | ប | | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៣២ | ងួន | បញ្ញារិទ្ធិ | ប | | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា |
| ៣៣ | ផន | សុភ័ក្រ | ប | | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា |
| ៣៤ | អ៊ូ | ច័ន្ទធារិទ្ធ | ប | | ក្រសួងបរិស្ថាន |
| ៣៥ | រីន | ពុទ្ធី | ប | | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៣៦ | គង់ | ប៊ុន្នី | ស | | ក្រសួងកិច្ចការនារី |

**ប្រការ២៖** បេក្ខជនទាំងពីរភេទដែលមានរាយនាមដូចក្នុងប្រការ១ ត្រូវមកបំពេញសំណុំឯកសារឲ្យបានត្រឹមថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ១២:០០ ថ្ងៃត្រង់ ជាកំហិត។

**ប្រការ៣៖** បេក្ខជនទាំងពីរភេទដែលបានមកបំពេញសំណុំឯកសារគ្រប់គ្រាន់ និងក្នុងករណីត្រូវបានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនធ្វើការវាយតម្លៃសម្រេចផ្តល់សិទ្ធិឲ្យប្រឡង ត្រូវគោរពរាល់បទបញ្ញត្តិ និងសេចក្តីណែនាំក្នុងពេលប្រឡងឲ្យបានល្អប្រសើរបំផុត។

**ប្រការ៤៖** នាយកសាលាភូមិន្ទរដ្ឋបាល និងអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានឈ្មោះខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៦

**កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន**